# ការប្រែក្លាយជាពួកអ្នកកាន់បព្វជិតភាពដែលមានអានុភាព

អែលឌើរ រ៉ុលធើរ អែហ្វ ហ្គុងស្សាឡេស្ស
ពីគណៈប្រធានពួក 70 នាក់

*យើងអាច ប្រែក្លាយកាន់តែមានអានុភាពនៅក្នុងការប្រទានពរជ័យដល់ជីវិតទាំងឡាយ នៃពួកបុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌ កាន់តែមានអានុភាពក្នុងការបំរើអ្នកដទៃ ។*

ជាច្រើនឆ្នាំកន្លងទៅហើយ មានក្រុមអ្នកកាន់បព្វជិតភាពដ៏សក្តិសមមួយបានបង្រៀនដោយអានុភាព និងសិទ្ធិអំណាចដ៏មហិមា ។ ក្នុងចំណោមពួកគាត់ មានម្នាក់ដែលមានអានុភាពយ៉ាងខ្លាំងដែលធ្វើឱ្យមនុស្សមិនអាចមិនជឿលើពាក្យរបស់គាត់ឡើយ ។1 ពួកអ្នកកាន់បព្វជិតភាពទាំងនេះបានជួយមនុស្សរៀនអំពីព្រះអង្គសង្គ្រោះ និងគោលលទ្ធិរបស់ទ្រង់ ហើយជួយឱ្យពួកគេរកឃើញសុភមង្គល ។ ការបង្រៀន និងគំរូរបស់ពួកគាត់ផ្តល់នូវមធ្យោបាយដើម្បីឱ្យមនុស្សអាច ទទួលបានបទពិសោធន៍នៃការផ្លាស់ប្តូរដ៏ធំក្នុងដួងចិត្ត ។ យើងរៀនថា មនុស្សរាប់ពាន់នាក់បានត្រូវដឹកនាំដោយពួកគេ ទៅធ្វើបុណ្យជ្រមុជទឹក ហើយចុះសេចក្តីសញ្ញាដើម្បីស៊ូទ្រាំរហូតដល់ទីបញ្ចប់ ។2 ខ្ញុំកំពុងនិយាយអំពីពួកអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យនៅក្នុងព្រះគម្ពីរមរមន ដែលជាពួកអ្នកកាន់បព្វជិតភាពដ៏មានអានុភាព ។

យើងអាចរៀនច្រើនពីកូនចៅរបស់លីហៃទាំងនេះ ។ តាមរយៈការធ្វើអ្វីដែលពួកលោកបានធ្វើ យើងអាចប្រែក្លាយកាន់តែមានអានុភាពនៅក្នុងការប្រទានពរជ័យដល់ជីវិតទាំងឡាយនៃពួកបុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌ កាន់តែមានអានុភាពក្នុងការបំរើអ្នកដទៃ កាន់តែមានអានុភាពលើការសង្គ្រោះអ្នកដទៃ ហើយកាន់តែមានអានុភាពថែមទៀតក្នុងការប្រែក្លាយជាបុរសឱ្យកាន់តែដូចព្រះគ្រីស្ទ ។

អាល់ម៉ា ជាកូនបានបង្រៀនយើងពីកិច្ចការមួយដែលពួកគេបានធ្វើដើម្បីទទួលបានជោគជ័យយ៉ាងខ្លាំងថា : ពួកគេបានប្រើកំណត់ត្រាដែលព្រះគម្ពីរមរមនបានចាប់ផ្តើមឡើងពីនោះ ។ នៅពេលលោកបានផ្តល់នូវកំណត់ត្រា ដែលនៅទីបំផុតបានក្លាយជាព្រះគម្ពីរមរមនទៅឱ្យកូនប្រុសរបស់គាត់ ហេលេមិន គាត់បានបង្រៀនថាបើគ្មានកំណត់ត្រានេះទេ "អាំម៉ូន និង បងប្អូនលោកក៏មិនអាចបរិវត្តពួកលេមិនជាច្រើននាក់... មែនហើយ បញ្ជីទាំងនេះ និងពាក្យនៅក្នុងនោះបាននាំពួកគេ ទៅកាន់ការប្រែចិត្ត" ។3

ព្រះបានបង្ហាញព្រះចេស្តាររបស់ទ្រង់ តាមរយៈផ្ទាំងមាសដោយការបំពេញគោលបំណងមួយ "គឺការនាំ... ច្រើនពាន់នាក់ ឱ្យស្គាល់សេចក្តីពិត" ។ បន្ទាប់មកអាលម៉ាបានព្យាករណ៍ថា ព្រះនឹង"នៅតែបង្ហាញព្រះចេស្តារបស់ទ្រង់ក្នុង[វា]ទៅដល់អ្នកជំនាន់ក្រោយៗទៀត" ។4 ហេតុដូច្នោះហើយ កំណត់ត្រាត្រូវបានថែរក្សាទុក ហើយរូបអ្នក និងខ្ញុំគឺជាផ្នែកមួយនៅក្នុងចំណោមអ្នកជំនាន់ក្រោយៗទាំងនោះ ។ គឺដូចជានៅសម័យបុរាណផងដែរ យើងអាចក្លាយជាអ្នកកាន់បព្វជិតភាពដែលមានអានុភាពតាមរយៈការប្រើប្រាស់ព្រះគម្ពីរមរមន ។

ដំណើរការនៃការបើកសម្តែងព្រះគម្ពីរមរមន គឺពុំអាចប្រៀបធៀបទៅនឹងកិច្ចការអក្សរសាស្ត្រណាមួយ ដោយអ្នកនិពន្ធនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សបានឡើយ ។ យើងអាចនិយាយបានថា ព្រះគម្ពីរមរមនគឺជាគម្ពីរដែលត្រូវបានការពារដោយអង្គុលីនៃ

ព្រះរបស់យើង។ នៅអំឡុងពេលទ្រង់យាងទៅជួបប្រជាជនអាមេរិកពីបុរាណ ព្រះអម្ចាស់បានប្រាប់នីហ្វៃឱ្យនាំយកកំណត់ត្រាដែលពួកគេបានរក្សាទុក ហើយដាក់បង្ហាញនៅចំពោះព្រះភ័ក្ត្រទ្រង់។ បន្ទាប់មក ព្រះយេស៊ូវបានទតមើលកំណត់ត្រាទាំងនោះ ហើយបានចេញព្រះរាជបញ្ជាថា ព្រឹត្តិការណ៍ និងសារលិខិតមួយចំនួនត្រូវតែដាក់បន្ថែម ។5 "ហើយទ្រង់មានព្រះបន្ទូលថា: បទគម្ពីរទាំងនេះ ដែលអ្នករាល់គ្នាពុំទាន់មាន នោះព្រះវរបិតាទ្រង់ បានបញ្ជាឱ្យយើងប្រទានដល់អ្នក ត្បិតនេះជាប្រាជ្ញានៅក្នុងទ្រង់ ដែលរបស់ទាំងនេះត្រូវបានប្រទានដល់មនុស្សជំនាន់ក្រោយ"។ 6 ខ្ញុំមានអំណរគុណដ៏នៅអស់កល្បជានិច្ច ដែលមានចំណែកនៅក្នុងជំនាន់ក្រោយកាលទាំងនោះ។ ខ្ញុំគឺជា សមាជិកនៃសាសនាចក្រសព្វថ្ងៃនេះ ដោយសារព្រះគម្ពីរមរមន។ ខ្ញុំមិនអាចបំភ្លេចបាននូវអារម្មណ៍របស់ខ្ញុំ កាលពីនៅក្មេងក្នុងប្រទេសអ៊ុយក្រាហ្គាយ ដែលខ្ញុំបានអានគម្ពីរដ៏ពិសិដ្ឋនេះជាលើកដំបូង។ ខ្ញុំពុំចាំបាច់អានច្រើននៅក្នុងនីហ្វៃទី 1 ដើម្បីទទួលនូវបទពិសោធន៍ដ៏រីករាយបែបនេះទេ ដែលពុំអាចរៀបរាប់ជាពាក្យពេចន៍បានឡើយ។ វាហាក់ដូចជាគម្ពីរនេះគឺត្រូវបានបំពេញដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ ហើយវាបានធ្វើឱ្យខ្ញុំមានអារម្មណ៍នៅជិតនឹងព្រះ។

បទពិសោធន៍នេះបន្ថែមអត្ថន័យចំពោះសេចក្តីថ្លែងដែលធ្វើឡើងដោយព្យាការី យ៉ូសែប ស៊្មីធ អំពីសៀវភៅនេះ នៅពេលលោកបានប្រកាសថា "បុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយសារធ្វើតាមសិក្ខាបទទាំងឡាយនៃគម្ពីរនេះ ជាជាងគម្ពីរដទៃទាំងអស់" ។7 ខ្ញុំក៏ស្គាល់ពីសារៈសំខាន់នៃការសន្យារបស់ប្រធាន ថូម៉ាស អេស ម៉នសុន ផងដែរ នៅពេលលោកមានប្រសាសន៍ថា "នៅពេលយើងអានព្រះគម្ពីរមរមន ហើយនឹងព្រះគម្ពីរផ្សេងទៀត នៅពេលដែលយើងអនុវត្តតាមការបង្រៀន នោះយើងនឹងចេះពីគោលលទ្ធិ ត្បិតនេះគឺជាសេចក្តីសន្យារបស់យើង យើងនឹងដឹងថាតើកិច្ចការនោះមកពីមនុស្ស ឬថាមកពីព្រះ" ។8
ការសន្យាទាំងនេះនាំមកឱ្យយើងនូវសេចក្តីរីករាយសំរាប់ពេលឥឡូវនេះ និងសំរាប់អនាគតកាល។ នៅពេលខ្ញុំទទួលបានទីបន្ទាល់អំពីព្រះគម្ពីរមរមន អារម្មណ៍ដើមដំបូងដែលកើតមាន គឺជាបំណងប្រាថ្នា ដើម្បីអនុវត្តការបង្រៀននៃព្រះគម្ពីរនេះ ដោយការចុះសេចក្តីសញ្ញា។ ខ្ញុំបានចុះដោយការទទួលបុណ្យជ្រមុជទឹក និងបានបញ្ជាក់ជាសមាជិកនៃសាសនាចក្រ។ សេចក្តីសញ្ញាទាំងឡាយដែលបានធ្វើតាមរយៈពិធីការបព្វជិតភាព ព្រមជាមួយនឹងចំណេះដឹងដែលខ្ញុំទទួលបានមកអំពីព្រះគម្ពីរមរមនបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ។

កាលដែលព្រះអង្គសង្គ្រោះបានយាងទៅនៅទ្វីបអាមេរិកពីបុរាណនោះ ពុំមែនជារឿងគួរឱ្យភ្ញាក់ផ្អើលឡើយ ក្រៅពីការបង្រៀនគោលលទ្ធិ ទ្រង់បានប្រទានឱ្យនីហ្វៃ និងមនុស្សដទៃទៀតនូវសិទ្ធិអំណាចដើម្បីធ្វើបុណ្យជ្រមុជទឹក ។9 ម្យ៉ាងវិញទៀត គោលលទ្ធិ និងពិធីការទាំងឡាយគឺត្រូវដើរទន្ទឹមគ្នា។ ការអនុវត្តន៍ការបង្រៀនព្រះគម្ពីរមរមនដ៏ពេញលេញ តម្រូវឱ្យមានពិធីការបព្វជិតភាពព្រមជាមួយនឹងសេចក្តីសញ្ញាដែលជាប់ទាក់ទង។

មានសៀវភៅជាច្រើនដែលចេញលក់នៅលើទីផ្សារ ហើយបានក្លាយជាសៀវភៅដែលលក់ដាច់លំដាប់ខ្ពស់។ នៅពេលខ្លះ សៀវភៅទាំងនោះ បានទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សយ៉ាងខ្លាំង ឱ្យរង់ចាំការចេញលក់យ៉ាងអន្ទះសារ។ សៀវភៅប្រភេទនោះហាក់ដូចជាមានគ្រប់ទីកន្លែងនៅលើទីផ្សារ ហើយអាចមើលឃើញថា មនុស្សអានវានៅគ្រប់ទីកន្លែង។ ព្រះដោយព្រះប្រាជ្ញាដ៏គ្មានដែនកំណត់របស់ទ្រង់ បានរក្សាទុកព្រះគម្ពីរមរមន សំរាប់ជាប្រយោជន៍របស់យើង។ គោលបំណងវា គឺពុំមែនសំរាប់ក្លាយខ្លួនជាសៀវភៅដែលលក់ដាច់បំផុតនោះទេ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចបង្វែរសៀវភៅពិសិដ្ឋនេះ ឱ្យក្លាយជាសៀវភៅដែល

ចូលចិត្តអានជាងគេបំផុត និងជាសៀវភៅដែលអនុវត្តតាមបានប្រសើរបំផុតនៅក្នុងជីវិតរបស់យើង។ ខ្ញុំសូមផ្តល់យោបល់បីដែលអាចជួយយើងបង្វែរព្រះគម្ពីរមរមនទៅជាសៀវភៅដែលចូលចិត្តអាន និងជាសៀវភៅដែលបានអនុវត្តតាមជាងគេបំផុត ដែលនឹងផ្តល់អានុភាពលើយើងនៅសព្វថ្ងៃនេះ ឱ្យក្លាយខ្លួនកាន់តែជាពួកអ្នកកាន់បព្វជិតភាពដ៏មានអានុភាព ដូចជានៅសម័យបុរាណទាំងនោះ។

ទីមួយ ទទួលទានព្រះបន្ទូលនៃព្រះគ្រីស្ទ។ យើងត្រូវតែអានព្រះគម្ពីរមរមនដើម្បី "ទទួលទាននូវព្រះបន្ទូលទាំងឡាយ នៃព្រះគ្រីស្ទ ត្បិតមើលចុះ ព្រះបន្ទូលនៃព្រះគ្រីស្ទនឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ"។10 ការទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទគឺជាបទពិសោធន៍ដ៏ពិសេសមួយ។ នៅពេលយើងអាន ហើយស្វែងរកគោលការណ៍ និងគោលលទ្ធិដែលនឹងជួយយើងនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង នោះយើងនឹងទទួលបាន សេចក្តីរីករាយជាបន្តបន្ទាប់។ ឧទាហរណ៍ នៅពេលជំនាន់កំពុងពេញវ័យប្រឈមមុខនៅក្នុងការតទល់នឹងសម្ពាធពីមិត្តភក្តិ យើងអាចអានព្រះគម្ពីរមរមន ជាពិសេសចំពោះការបង្រៀនដែលនឹងជួយពួកគេនៅក្នុងការប្រឈមមុខបែបនេះ។ ការបង្រៀនមួយ អាចដកស្រង់ចេញពីបទពិសោធន៍របស់លេមយូល។ លេមយូល បានធ្វើការសំរេចចិត្តខុស ពីព្រោះគាត់ទោទន់តាមសម្ពាធរបស់លេមិន។11 គាត់ពុំបានធ្វើការណ៍ត្រឹមត្រូវដោយសារគាត់ "មិនបានដឹងអំពីព្រឹត្តិការណ៍នៃព្រះដែលបានបង្កើតពួកគេមក"។12 គោលការណ៍មួយដែលយើងអាចដកស្រង់ចេញពីហេតុការណ៍នេះគឺថា ការរៀនគោលលទ្ធិអំពីរបៀបព្រះធ្វើកិច្ចការទ្រង់ជាមួយយើងនឹងជួយយើងឱ្យចេះតទល់ជាមួយនឹងសម្ពាធពីមិត្តភក្តិ។ ព្រះគម្ពីរមរមនក៏មានការបង្រៀន និងគំរូបន្ថែមទៀតអំពីប្រធានបទនេះដែរ ហើយយើងគឺជាជំនាន់ដែលអាចទទួលផលប្រយោជន៍មកពីការបង្រៀននៃព្រះគម្ពីរនេះ។

ទីពីរ អនុវត្តតាមនៅក្នុងជីវិតរបស់យើងនូវអ្វីៗទាំងអស់ដែលយើងរៀនអំពីព្រះគ្រីស្ទ។ ការអានព្រះគម្ពីរមរមន និងការស្វែងរកបុគ្គលិកលក្ខណៈព្រះគ្រីស្ទគឺជាបទពិសោធន៍មហិមាមួយ។ ឧទាហរណ៍ បងប្រុសរបស់យ៉ារេឌបានដឹងថា ព្រះមានសេចក្តីពិត ហេតុដូច្នេះហើយ ទ្រង់ពុំកុហក់ឡើយ។13 ឱ! នេះគឺជាសេចក្តីសង្ឃឹមដ៏មហិមា ដែល បុគ្គលិកលក្ខណៈនេះបានផ្តល់ឱ្យព្រលឹងខ្ញុំ! សេចក្តីសន្យាទាំងអស់នៅក្នុងព្រះគម្ពីរមរមន និងសេចក្តីសន្យាទាំងឡាយ ដែលបានប្រទានឱ្យតាមពួកព្យាការីដែលនៅរស់សព្វថ្ងៃនេះនឹងត្រូវបានបំពេញ ដោយសារទ្រង់គឺជា ព្រះ ហើយពុំអាចកុហកឡើយ។ ទោះបីជានៅក្នុងពេលដ៏លំបាកទាំងនេះក្តី យើងដឹងថាអ្វីៗទាំងអស់នឹងមិនថ្វីទេ ប្រសិនបើយើងធ្វើតាម ការបង្រៀនដែលបានរៀនចេញពីគម្ពីរមរមន និងពួកព្យាការីដែលនៅរស់។ នៅពេលដែលយើងបានរៀនអំពីបុគ្គលិកលក្ខណៈនៃព្រះគ្រីស្ទ ដូចជាបុគ្គលិកលក្ខណៈមួយដែលបានទទួលស្គាល់ដោយបងប្រុសរបស់យ៉ារេឌ យើងគួរតែយកមកអនុវត្តនៅក្នុងជីវិតរបស់យើងផ្ទាល់។ ការណ៍នេះនឹងជួយយើងឱ្យក្លាយជាពួកអ្នកកាន់បព្វជិតភាពដែលមានអានុភាព។

ទីបី បង្រៀនគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលរកឃើញនៅក្នុងទំព័រពិសិដ្ឋពីគម្ពីរមរមន។ យើងអាចបង្រៀននរណាក៏បានដែរចេញពីគម្ពីរនេះ។ តើអ្នកអាចគិតស្រមៃឃើញនូវ"ព្រះចេស្តានៃព្រះដែលបរិវត្ត"14 បន្ថែមទៀតនៅពេលណាដែលពួកអ្នកផ្សព្វផ្សាយសាសនា និងសមាជិកគ្រួសារដកស្រង់ អាន ឬចងចាំក្នុងចិត្តនូវពាក្យពេចន៍នៅក្នុងគម្ពីរ?

ខ្ញុំនៅចាំពីបេសកកម្មមួយក្នុងប្រទេសអេក្វាឌ័រ ដែលពួកអ្នកផ្សព្វផ្សាយសាសនាបានប្រើប្រាស់គម្ពីរមរមន នៅគ្រប់សកម្មភាពរបស់ពួកគេទាំងអស់ ។ ដោយសារតែការធ្វើបែបនេះ មនុស្សរាប់ពាន់នាក់បានទទួលនូវបទពិសោធន៍នៃការផ្លាស់ប្តូរដ៏មហិមាក្នុងដួងចិត្ត ហើយសំរេចចិត្តចូលទៅក្នុងសេចក្តីសញ្ញា តាមរយៈពិធីការបព្វជិតភាពដ៏ពិសិដ្ឋ ។ ព្រះគម្ពីរមរមនគឺជា សេចក្តីណែនាំដ៏មានតម្លៃ នៅក្នុងការស្វែងរក និងផ្លាស់ប្រែចិត្តពួកអ្នកស្វែងរកសេចក្តីពិតដែលស្មោះត្រង់ និងជួយសង្គ្រោះដល់បងប្អូនប្រុសស្រីយើងជាច្រើននាក់ ឱ្យត្រឡប់មកធ្វើតាមសកម្មភាពដំណឹងល្អវិញ ។

ខ្ញុំដឹងថាក្រុមគ្រួសារទាំងឡាយនឹងត្រូវបានលើកស្ទួយ តាមរយៈការអនុវត្តន៍តាមការបង្រៀនចេញពីគម្ពីរនេះនៅក្នុងជីវិតរបស់ពួកគេ ។ កូនចៅរបស់យើងជាច្រើននឹងបានសង្គ្រោះ ដោយសារតែពួកគេនឹងចងចាំ ដូចជាអេណុស បានចាំនូវពាក្យពេចន៍ដែលគាត់បានឮឪពុករបស់គាត់និយាយជាញឹកញាប់ ទាក់ទិននឹងជីវិតដ៏នៅអស់កល្បជានិច្ច និងដោយសារតែពាក្យពេចន៍នេះ គាត់បានដឹងថាអំពើបាបទាំងឡាយរបស់គាត់ត្រូវបានអភ័យទោសឱ្យ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។15

អ្នក និងខ្ញុំក្នុងនាមជាអ្នកមានចំណែកនៅក្នុងជំនាន់នាពេលអនាគតដែលត្រូវបាននិយាយទាំងនោះ អាចក្លាយជាពួកអ្នកកាន់បព្វជិតភាពកាន់តែមានអានុភាព តាមរយៈការប្រើប្រាស់ព្រះគម្ពីរមរមន និងការគោរពសេចក្តីសញ្ញាបព្វជិតភាពរបស់យើង ។ ខ្ញុំដឹងថា ព្រះគម្ពីរមរមន ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវ ជាព្រះគ្រីស្ទ ដែលខ្ញុំក៏សូមថ្លែងទីបន្ទាល់ផងដែរ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល នីហ្វៃទី 3 7:18 ។
2. សូមមើល អាលម៉ា 23:5--6 ។
3. អាលម៉ា 37:9 ។
4. អាលម៉ា 37:19 ។
5. សូមមើល នីហ្វៃទី 3 23:6--14 ។
6. នីហ្វៃទី 3 26:2 ។
7. បុព្វកថាព្រះគម្ពីរមរមន ។
8. Thomas S. Monson "Decisions Determine Destiny" *New Era* ខែ វិច្ឆិកា ឆ្នាំ 1979 ទំព័រ 5 ។
9. សូមមើលនីហ្វៃទី 3 11:18--22 ។
10. នីហ្វៃទី 2 32:3 ។
11. សូមមើល នីហ្វៃទី 1 3:28 ។
12. នីហ្វៃទី 1 2:12 ។
13. សូមមើល អេធើរ 3:12 ។
14. នីហ្វៃទី 3 28:29 ។
15. សូមមើល អេណុស 1:3--5, 10 ។